# C006 - Night Work of Young Persons (Industry) Convention, 1919 (No. 6)

*Convention concerning the Night Work of Young Persons Employed in Industry (Entry into force: 13 Jun 1921) Adoption: Washington, 1st ILC session (28 Nov 1919) - Status: Instrument to be revised (Technical Convention).*

## Preamble

The General Conference of the International Labour Organisation,

Having been convened by the Government of the United States of America at Washington, on the 29 October 1919, and

Having decided upon the adoption of certain proposals with regard to the "employment of children: during the night", which is part of the fourth item in the agenda for the Washington meeting of the Conference, and

Having determined that these proposals shall take the form of an international Convention,

adopts the following Convention, which may be cited as the Night Work of Young Persons (Industry) Convention, 1919, for ratification by the Members of the International Labour Organisation in accordance with the provisions of the Constitution of the International Labour Organisation:

## Article 1

1. For the purpose of this Convention, the term ***industrial undertaking*** includes particularly--

- (a) mines, quarries and other works for the extraction of minerals from the earth;
- (b) industries in which articles are manufactured, altered, cleaned, repaired, ornamented, finished, adapted for sale, broken up, or demolished, or in which materials are transformed; including shipbuilding, and the generation, transformation, and transmission of electricity or motive power of any kind;
- (c) construction, reconstruction, maintenance, repair, alteration, or demolition of any building, railway, tramway, harbour, dock, pier, canal, inland waterway, road, tunnel, bridge, viaduct, sewer, drain, well, telegraphic or telephonic installation, electrical undertaking, gas work, water work, or other work of construction as well as the preparation for or laying the foundations of any such work or structure;
- (d) transport of passengers or goods by road or rail, including the handling of goods at docks, quays, wharves, and warehouses, but excluding transport by hand.

2. The competent authority in each country shall define the line of division which separates industry from commerce and agriculture.

## Article 2

1. Young persons under eighteen years of age shall not be employed during the night in any public or private industrial undertaking, or in any branch thereof, other than an undertaking in which only members of the same family are employed, except as hereinafter provided for.

2. Young persons over the age of sixteen may be employed during the night in the following industrial undertakings on work which, by reason of the nature of the process, is required to be carried on continuously day and night:

- (a) manufacture of iron and steel; processes in which reverberatory or regenerative furnaces are used, and galvanising of sheet metal or wire (except the pickling process);
- (b) glass works;
- (c) manufacture of paper;

- (d) manufacture of raw sugar;
- (e) gold mining reduction work.

## Article 3

1. For the purpose of this Convention, the term ***night*** signifies a period of at least eleven consecutive hours, including the interval between ten o'clock in the evening and five o'clock in the morning.

2. In coal and lignite mines work may be carried on in the interval between ten o'clock in the evening and five o'clock in the morning, if an interval of ordinarily fifteen hours, and in no case of less than thirteen hours, separates two periods of work.

3. Where night work in the baking industry is prohibited for all workers, the interval between nine o'clock in the evening and four o'clock in the morning may be substituted in the baking industry for the interval between ten o'clock in the evening and five o'clock in the morning.

4. In those tropical countries in which work is suspended during the middle of the day, the night period may be shorter than eleven hours if compensatory rest is accorded during the day.

## Article 4

The provisions of Articles 2 and 3 shall not apply to the night work of young persons between the ages of sixteen and eighteen years in case of emergencies which could not have been controlled or foreseen, which are not of a periodical character, and which interfere with the normal working of the industrial undertaking.

## Article 5

In the application of this Convention to Japan, until 1 July 1925, Article 2 shall apply only to young persons under fifteen years of age and thereafter it shall apply only to young persons under sixteen years of age.

## Article 6

In the application of this Convention to India, the term "industrial undertaking" shall include only "factories" as defined in the Indian Factory Act, and Article 2 shall not apply to male young persons over fourteen years of age.

## Article 7

The prohibition of night work may be suspended by the Government, for young persons between the ages of sixteen and eighteen years, when in case of serious emergency the public interest demands it.

## Article 8

The formal ratifications of this Convention, under the conditions set forth in the Constitution of the International Labour Organisation, shall be communicated to the Director-General of the International Labour Office for registration.

## Article 9

1. Each Member of the International Labour Organisation which ratifies this Convention engages to apply it to its colonies, protectorates and possessions which are not fully self-governing--

- (a) except where owing to the local conditions its provisions are inapplicable; or
- (b) subject to such modifications as may be necessary to adapt its provisions to local conditions.

2. Each Member shall notify to the International Labour Office the action taken in respect of each of its colonies, protectorates, and possessions which are not fully self-governing.

## Article 10

As soon as the ratifications of two Members of the International Labour Organisation have been registered with the International Labour Office, the Director-General of the International Labour Office shall so notify all the Members of the International Labour Organisation.

## Article 11

This Convention shall come into force at the date on which such notification is issued by the Director-General of the International Labour Office, and it shall then be binding only upon those Members which have registered their ratifications with the International Labour Office. Thereafter this Convention will come into force for any other Member at the date on which its ratification is registered with the International Labour Office.

## Article 12

Each Member which ratifies this Convention agrees to bring its provisions into operation not later than 1 July 1922, and to take such action as may be necessary to make these provisions effective.

## Article 13

A Member which has ratified this Convention may denounce it after the expiration of ten years from the date on which the Convention first comes into force, by an act communicated to the Director-General of the International Labour Office for registration. Such denunciation shall not take effect until one year after the date on which it is registered with the International Labour Office.

## Article 14

At such times as it may consider necessary the Governing Body of the International Labour Office shall present to the General Conference a report on the working of this Convention and shall examine the desirability of placing on the agenda of the Conference the question of its revision in whole or in part.

## Article 15

The French and English texts of this Convention shall both be authentic.

# នុសញ្ញាលេខ ៦

# អនុសញ្ញាស្តីពីការងារពេលយប់របស់មនុស្សវ័យក្មេង ឆ្នាំ១៩១៩ (លេខ៦)

*អនុសញ្ញាស្តីពីការងារពេលយប់របស់មនុស្សវ័យក្មេង (ចូលជាធរមាន ៖ ថ្ងៃទី ១៣ មិថុនា ឆ្នាំ ១៩២១) អនុម័តនៅក្នុងសម័យប្រជុំនៃសន្និសីទអន្តរជាតិខាងការងារលើក១ នៅទីក្រុងវ៉ាស៊ីនតោន (នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ ១៩១៩) - ស្ថានភាព ៖ លិខិតុបករណ៍ដែលនឹងត្រូវកែសម្រួល (អនុសញ្ញាបច្ចេកទេស)*

សន្និសីទសាកលនៃអង្គការអន្តរជាតិខាងការងារ

បានឃើញការកោះប្រជុំនៅទីក្រុងវ៉ាស៊ីនតោនដោយរដ្ឋាភិបាលសហរដ្ឋអាមេរិកនាថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩១៩ និង

បានឃើញការអនុម័តលើសំណើមួយចំនួនស្តីពី "ការងារពេលយប់របស់មនុស្សវ័យក្មេង" ដែលជាផ្នែកមួយនៃចំណុចទីបួនក្នុងរបៀបវារៈរបស់សម័យប្រជុំនៃសន្និសីទនៅទីក្រុងវ៉ាស៊ីនតោន និងបានកំណត់ថា សំណើទាំងនេះត្រូវមានទម្រង់ជាអនុសញ្ញាអន្តរជាតិ

អនុម័តអនុសញ្ញា ដែលហៅថា អនុសញ្ញាស្តីពីការងារពេលយប់របស់មនុស្សវ័យក្មេង (ឧស្សាហកម្ម) ឆ្នាំ១៩១៩ សម្រាប់រដ្ឋជាសមាជិកនៃអង្គការអន្តរជាតិខាងការងារផ្តល់សច្ចាប័ន ដោយអនុលោមតាមបញ្ញត្តិនៃធម្មនុញ្ញរបស់អង្គការអន្តរជាតិខាងការងារ ៖

១. សម្រាប់គោលបំណងនៃអនុសញ្ញានេះ ពាក្យ *គ្រឹះស្ថានឧស្សាហកម្ម* រួមមាន ៖

(ក) រ៉ែ ការដ្ឋានវាយថ្ម និងការងារផ្សេងទៀតសម្រាប់ការទាញយករ៉ែពីក្នុងដី។

(ខ) ឧស្សាហកម្មដែលក្នុងនោះវត្ថុត្រូវបានផលិតឡើង កែច្នៃ សម្អាត ជួសជុល កែលម្អ ផលិតសម្រេច កែសម្រួល បំបែក ឬកម្ទេច ឬដែលក្នុងនោះសម្ភារៈត្រូវ

បានប្លែង រួមទាំងការសាងសង់នាវា និងការបង្កើត ការផ្លាស់ប្តូរ និងការបញ្ជូនអគ្គិសនី ឬថាមពលនៃកំលាំងចលករប្រភេទណាមួយ។

(គ) សំណង់ ការសាងសង់ឡើងវិញ ការថែរក្សា ការជួសជុល ការកែសម្រួល ឬការវាយកម្ទេចសំណង់អាគារ ផ្លូវរថភ្លើង អយរថអគ្គិសនី កំពង់ផែ ចំណតកំពង់ផែ សំណង់ផែ ប្រឡាយ ផ្លូវទឹក ផ្លូវគោក ផ្លូវរូង ស្ពាន ស្ពានកាត់ជ្រលងភ្នំ លូទឹកសំអុយ លូបង្ហូរទឹក អណ្តូង ការដំឡើងទូរពុម្ព ឬទូរស័ព្ទ រោងចក្រអគ្គិសនី ការងារឧស្ម័ន ការងារទឹក ឬការងារសាងសង់ដទៃទៀត ព្រមទាំងការរៀបចំសម្រាប់បុកគ្រឹះនៃការងារ ឬគ្រោងសំណង់ទាំងនោះ។

(ឃ) ការដឹកជញ្ជូនអ្នកដំណើរ ឬទំនិញតាមផ្លូវគោក ឬផ្លូវរថភ្លើង រួមទាំងការប្រគល់ទំនិញនៅចំណតកំពង់ផែ កំពង់ផែ និងឃ្លាំង ប៉ុន្តែមិនរួមបញ្ចូលការដឹកជញ្ជូនដោយដៃឡើយ។

២. អាជ្ញាធរមានសមត្ថកិច្ចនៅក្នុងរដ្ឋនីមួយៗត្រូវកំណត់បែងចែករវាងឧស្សាហកម្ម ពាណិជ្ជកម្ម និងកសិកម្ម។

## មាត្រា២

១. មនុស្សវ័យក្មេងដែលមានអាយុក្រោមដប់ប្រាំបីឆ្នាំ មិនត្រូវជួលឲ្យធ្វើការនៅពេលយប់នៅក្នុងគ្រឹះស្ថានឧស្សាហកម្មសាធារណៈ ឬឯកជនណាមួយ ឬនៅសាខាណាមួយផ្សេងទៀត លើកលែងតែសហគ្រាសដែលនៅក្នុងនោះមានសមាជិកមកពីគ្រួសារតែមួយត្រូវបានជួល។

២. មនុស្សវ័យក្មេងដែលមានអាយុលើសពីដប់ប្រាំមួយឆ្នាំ អាចត្រូវបានជួលឲ្យធ្វើការនៅពេលយប់នៅក្នុងគ្រឹះស្ថានឧស្សាហកម្មខាងក្រោម ចំពោះការងារដែលតម្រូវឲ្យអនុវត្តការងារនោះទាំងពេលថ្ងៃ និងពេលយប់ជាបន្តឥតឈប់ ដោយសារតែលក្ខណៈដំណើរការការងារនោះ ៖

(ក) រោងចក្រផលិតដែក និងដែកថែប ដែលដំណើរការដោយឡដុតកំដៅប្រើចំហាយភ្លើង ឬប្រើហ្គាស និងការពាសសំណប៉ាហាំងលើបន្ទះដែក ឬខ្សែភ្លើង (លើកលែងតែដំណើរការសម្អាតច្រេះចេញពីដែក)។

(ខ) រោងចក្រកែវ

(គ) រោងចក្រក្រដាស

(ឃ) រោងចក្រស្ករ

(ង) ការដ្ឋានចម្រាញ់យករ៉ែមាស

## មាត្រា ៣

១. សម្រាប់គោលបំណងនៃអនុសញ្ញានេះ ពាក្យ *ពេលយប់* សំដៅដល់រយៈពេលយ៉ាងតិចដប់មួយម៉ោងជាប់ៗគ្នា រួមទាំងចន្លោះពេលពីម៉ោងដប់យប់ និងម៉ោងប្រាំព្រឹក។

២. ក្នុងការដ្ឋានរ៉ែធ្យូងថ្ម និងរ៉ែលីញីត ការងារអាចនឹងត្រូវបានធ្វើឡើងនៅចន្លោះពីម៉ោងដប់យប់ និង ប្រាំព្រឹក ប្រសិនបើចន្លោះពេលធ្វើការជាធម្មតាមានដប់ប្រាំម៉ោង ហើយមិនត្រូវតិចជាងដប់បីម៉ោង រវាងពេលធ្វើការទាំងពីរនេះឡើយ។

៣. ប្រសិនបើការងារពេលយប់នៅក្នុងឧស្សាហកម្មដុតនំ ត្រូវបានហាមឃាត់ចំពោះកម្មករទាំងអស់ ចន្លោះពេលពីម៉ោងប្រាំបួនល្ងាច និងបួនព្រឹក អាចត្រូវបានជំនួសដោយចន្លោះពេលពីម៉ោងដប់ល្ងាច និងម៉ោងប្រាំព្រឹកនៅក្នុងឧស្សាហកម្មដុតនំ។

៤. នៅក្នុងបណ្តាប្រទេសក្នុងតំបន់ត្រូពិក ដែលការងារត្រូវបានផ្អាកនៅពេលថ្ងៃត្រង់នោះ ការងារនៅពេលយប់ត្រូវតិចជាងដប់មួយម៉ោង ប្រសិនបើការសម្រាកជាសំណងត្រូវបានធ្វើឡើងនៅពេលថ្ងៃ។

## មាត្រា ៤

បញ្ញត្តិក្នុងមាត្រា ២ និង៣ មិនត្រូវអនុវត្តចំពោះការងារពេលយប់របស់មនុស្សវ័យក្មេងដែលមានអាយុពីដប់ប្រាំមួយឆ្នាំដល់ដប់ប្រាំបីឆ្នាំឡើយក្នុងករណីបន្ទាន់ដែលមិនអាចគ្រប់គ្រង ឬព្យាករបាន ដែលមិនមែនកើតឡើងជាប្រចាំ និងដែលរារាំងដល់ការធ្វើការងារធម្មតារបស់គ្រឹះស្ថានឧស្សាហកម្ម។

## មាត្រា ៥

នៅក្នុងការអនុវត្តអនុសញ្ញានេះនៅប្រទេសជប៉ុន នៅត្រឹមថ្ងៃទី១ ខែកក្កដា ឆ្នាំ១៩២៥ មាត្រា ២ ត្រូវអនុវត្តចំពោះតែមនុស្សវ័យក្មេងដែលមានអាយុក្រោមដប់ប្រាំឆ្នាំ ដូច្នេះហើយ អនុសញ្ញានេះអាចអនុវត្តចំពោះតែជនវ័យក្មេងដែលមានអាយុក្រោមដប់ប្រាំមួយឆ្នាំប៉ុណ្ណោះ។

## មាត្រា ៦

នៅក្នុងការអនុវត្តអនុសញ្ញានេះនៅក្នុងប្រទេសឥណ្ឌា ពាក្យ "គ្រឹះស្ថានឧស្សាហកម្ម" ត្រូវរួមបញ្ចូលតែ "រោងចក្រ" ប៉ុណ្ណោះ ដូចបានកំណត់ក្នុងច្បាប់ស្តីពីរោងចក្រនៅប្រទេសឥណ្ឌា ហើយមាត្រា ២ មិនត្រូវអនុវត្តចំពោះក្មេងប្រុសដែលមានអាយុលើសពីដប់បួនឆ្នាំឡើយ។

## [illegible]

ការហាមឃាត់នៃការងារពេលយប់ អាចត្រូវបានផ្អាកដោយរដ្ឋាភិបាលចំពោះមនុស្សវ័យក្មេង អាយុពីដប់ប្រាំមួយឆ្នាំដល់ដប់ប្រាំបីឆ្នាំ នៅពេលតម្រូវឲ្យមានការផ្អាកនោះ ដោយសារករណីបន្ទាន់។

## [illegible]

ការផ្តល់សច្ចាប័នផ្លូវការនៃអនុសញ្ញានេះ ដោយអនុលោមតាមលក្ខខណ្ឌដូចមានចែងក្នុងធម្មនុញ្ញរបស់អង្គការអន្តរជាតិខាងការងារ ត្រូវផ្ញើជូនទៅអគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារសម្រាប់ចុះបញ្ជិកា។

## មាត្រា ៨

១. រដ្ឋជាសមាជិកនីមួយៗរបស់អង្គការអន្តរជាតិខាងការងារ ដែលផ្តល់សច្ចាប័នដល់អនុសញ្ញានេះ យល់ព្រមអនុវត្តអនុសញ្ញានេះនៅក្នុងដែនដីក្រោមអាណានិគម ដែនដីក្រោមការត្រួតត្រា និងដែនដីជាកម្មសិទ្ធិ ដែលមិនស្ថិតក្រោមការគ្រប់គ្រងទាំងស្រុងរបស់ខ្លួន ៖

(ក) លើកលែងតែដោយផ្អែកលើលក្ខខណ្ឌក្នុងប្រទេស បញ្ញត្តិអនុសញ្ញា មិនអាចអនុវត្តបាន ឬ

(ខ) ត្រូវធ្វើការកែសម្រួលបញ្ញត្តិដើម្បីឲ្យស្របនឹងលក្ខខណ្ឌក្នុងរដ្ឋរបស់ខ្លួន។

២. រដ្ឋជាសមាជិកនីមួយៗត្រូវជូនដំណឹងដល់ការិយាល័យអន្តរជាតិខាងការងារនូវវិធានការដែលបានអនុវត្ត នៅក្នុងដែនដីក្រោមអាណានិគម ដែនដីក្រោមការត្រួតត្រា និងដែនដីជាកម្មសិទ្ធិ ដែលមិនស្ថិតក្រោមការគ្រប់គ្រងទាំងស្រុងរបស់ខ្លួន។

## [illegible]

បន្ទាប់ពីការផ្តល់សច្ចាប័នរបស់រដ្ឋសមាជិកចំនួនពីរនៃអង្គការអន្តរជាតិខាងការងារ ត្រូវបានចុះបញ្ជិកានៅការិយាល័យអន្តរជាតិខាងការងារ អគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារក៏ត្រូវជូនដំណឹងដល់រដ្ឋជាសមាជិកទាំងអស់របស់អង្គការអន្តរជាតិខាងការងារផងដែរ។

## [illegible]

អនុសញ្ញានេះ ត្រូវចូលជាធរមាននៅកាលបរិច្ឆេទដែលការផ្តល់សច្ចាប័ននេះត្រូវបានចេញដោយអគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារ ប៉ុន្តែអនុសញ្ញានេះត្រូវចងកាតព្វកិច្ច

ចំពោះតែរដ្ឋជាសមាជិកនៃអង្គការអន្តរជាតិខាងការងារណាដែលសច្ចាប័នរបស់ខ្លួនត្រូវបានចុះបញ្ជិកាជាមួយការិយាល័យអន្តរជាតិខាងការងារប៉ុណ្ណោះ។ ដូច្នេះ អនុសញ្ញានេះនឹងចូលជាធរមានសម្រាប់រដ្ឋជាសមាជិកផ្សេងទៀត នៅកាលបរិច្ឆេទដែលការផ្តល់សច្ចាប័នរបស់រដ្ឋជាសមាជិកនោះត្រូវបានចុះបញ្ជិកានៅការិយាល័យអន្តរជាតិខាងការងារ។

## មាត្រា ១២

រដ្ឋជាសមាជិកនីមួយៗដែលផ្តល់សច្ចាប័នដល់អនុសញ្ញានេះ យល់ព្រមអនុវត្តបញ្ញត្តិនៃអនុសញ្ញានេះយ៉ាងយូរបំផុតត្រឹមថ្ងៃទី១ កក្កដា ឆ្នាំ១៩២២ និងត្រូវអនុវត្តវិធានការចាំបាច់ទាំងនេះដើម្បីឲ្យបញ្ញត្តិនេះចូលជាធរមាន។

## មាត្រា ១៣

រដ្ឋជាសមាជិកមួយ ដែលបានផ្តល់សច្ចាប័នលើអនុសញ្ញានេះរួចហើយ អាចធ្វើអប្បដិបត្តិកម្មអនុសញ្ញានេះ បន្ទាប់ពីការផុតរលត់នៃអំឡុងពេលដប់ឆ្នាំគិតពីកាលបរិច្ឆេទដែលអនុសញ្ញានេះចូលជាធរមានលើកទីមួយ ដោយផ្ញើលិខិតជូនទៅអគ្គនាយកនៃការិយាល័យអន្តរជាតិខាងការងារ ដើម្បីចុះបញ្ជិកា។ អប្បដិបត្តិកម្មនេះ នឹងមិនមានសុពលភាពរហូតរយៈពេលមួយឆ្នាំបន្ទាប់ពីកាលបរិច្ឆេទនៃអប្បដិបត្តិកម្មនេះបានចុះបញ្ជិកានៅការិយាល័យអន្តរជាតិខាងការងារ។

## មាត្រា ១៤

នៅពេលពិនិត្យឃើញថាមានការចាំបាច់ ក្រុមប្រឹក្សាភិបាលនៃការិយាល័យអន្តរជាតិខាងការងារ ត្រូវធ្វើរបាយការណ៍ជូនសន្និសីទសាកលអំពីដំណើរការអនុវត្តអនុសញ្ញានេះព្រមទាំងពិនិត្យលទ្ធភាពដាក់ក្នុងរបៀបវារៈនៃសន្និសីទនូវសំណើសុំពិនិត្យកែលម្អខ្លឹមសារនៃអនុសញ្ញាទាំងស្រុង ឬដោយផ្នែកខ្លះ។

## មាត្រា ១៥

អត្ថបទជាភាសាអង់គ្លេស និងភាសាបារាំងនៃអនុសញ្ញានេះ ត្រូវទុកជាបន្ទាល់ដូចគ្នា។